# អាមីរុល-មុមីនីន صلوات الله عليه والسلام

# អាលី صلوات الله عليه والسلام ប៊ិន អាប៊ូ ត៏លិប رضي الله عنه

# អធិប្បាយអំពីស៏ឡាត់

روى جابر بن عبد الله الأنصاري قال: كنت مع مولانا أمير المؤمنين (عليه السلام)، فرأى رجلا قائما يصلي، فقال له: (يا هذا أتعرف تأويل الصلاة)، فقال: يا مولاي وهل للصلاة تأويل غير العبادة؟ فقال: (إي والذي بعث محمدا (صلى الله عليه وآله) بالنبوة، ما بعث الله نبيه بأمر من الأمور الا وله تشابه، وتأويل، وتنزيل، وكل ذلك يدل على التعبد)، فقال له: علمني ما هو يا مولاي؟ فقال: (تأويل تكبيرتك الأولى إلى احرامك، ان تخطر في نفسك إذا قلت الله أكبر من أن يوصف بقيام أو قعود، وفي الثانية: أن يوصف بحركة أو جمود، وفي الثالثة: أن يوصف بجسم، أو يشبه بشبه، أو يقاس بقياس، وتخطر في الرابعة: ان تحله الاعراض، أو تؤلمه الأمراض، وتخطر في الخامسة: أن يوصف بجوهر، أو عرض، أو يحل شيئا، أو يحل فيه شئ، وتخطر في السادسة: ان يجوز عليه ما يجوز على المحدثين من الزوال، والانتقال، والتغير من حال إلى حال، وتخطر في السابعة: أن تحله الحواس الخمس. ثم تأويل مد عنقك في الركوع، تخطر في نفسك: آمنت بك ولو ضربت عنقي. ثم تأويل رفع رأسك من الركوع، إذا قلت: سمع الله لمن حمده، الحمد لله رب العالمين، تأويله: الذي أخرجني من العدم إلى الوجود، وتأويل السجدة الأولى: ان تخطر في نفسك وأنت ساجد: منها خلقتني، ورفع رأسك تأويله ومنها أخرجتني، والسجدة الثانية: وفيها تعيدني، ورفع رأسك تخطر بقلبك ومنها تخرجني تارة أخرى. وتأويل قعودك على جانبك الأيسر، ورفع رجلك اليمنى، وطرحك على اليسرى تخطر بقلبك: اللهم أني أقمت الحق، وأمت الباطل، وتأويل تشهدك: تجديد الايمان، ومعاودة الاسلام، والاقرار بالبعث بعد الموت، وتأويل قراءة التحيات: تمجيد الرب سبحانه، وتعظيمه عما قال الظالمون، ونعته الملحدون. وتأويل قولك: السلام عليكم ورحمة الله وبركاته: ترحم عن الله سبحانه، فمعناها هذه أمان لكم من عذاب يوم القيامة. ثم قال أمير المؤمنين (عليه السلام): من لم يعلم تأويل صلاته هكذا، فهي خداج أي ناقصة.

مستدرك الوسائل ج: ٤ صفحة: ١٠٧ و ١٠٨

យ៉ាបៀរ ប៊ិន អាប់ឌុលឡោះហ៍ អាល់-អាន់ស្ស៊ារីបានថ្លែងថាខ្ញុំបាននៅជុំជាមួយអាមីរុល-មុមីនីន صلوات الله عليه والسلام (គឺអាលី صلوات الله عليه والسلام ប៊ិន អាប៊ូ តា៏លិប رضي الله عنه) ។ ព្រះបរមគ្រូ صلوات الله عليه والسلام ខ្ញុំបានឃើញបុរសម្នាក់ស្ស៊ឡាត់ បានសួរបុរសនោះថា៖ «តើ

អ៊ីស្លាមបន្តទៅមុខទៀត ហើយយល់ព្រមទទួលការស្លាប់និងការរស់ឡើងវិញបន្ទាប់ពីស្លាប់ ។ នៅក្នុង "តាស៊ុយ៉ាត់" យើងស្ងើចសរសើរអល់ឡោះហ៍ عزّ وجلّ សូមខមាទោសព្រះអង្គ عزّ وجلّ សូមឲ្យព្រះអង្គ عزّ وجلّ ការពារយើងទល់នឹងពួកសង្កត់សង្កិននិងអន្ទាក់កំណាចរបស់ពួកវា ។ រីឯន័យរបស់ "السلام عليكم و رحمة الله و بركاته" លោកសូមឲ្យអល់ឡោះហ៍ عزّ وجلّ ការពារយើងឲ្យរួចផុតពីទណ្ឌកម្មថ្ងៃគីយ៉ាម៉ាត់ ហើយសូមឲ្យព្រះអង្គ عزّ وجلّ ប្រសិទ្ធពរដល់យើង ។» ទីបំផុត អាមីរុល–មុមីនីន صلوات الله عليه والسلام មានវចនៈថា៖ «អ្នកណាមិនដឹងន័យរបស់ស៊ូឡាត់ ខ្លួនទេ ស៊ូឡាត់របស់អ្នកនោះខ្សោយមិនពេញលេញទេ ។»



លោកស្គាល់ន័យស៊ូឡាត់លោកទេ ?» បុរសនោះបានទូលថា៖ «ព្រះបរមគ្រូអើយ صلوات الله عليه والسلام ន័យរបស់ស៊ូឡាត់មិនមែនស្ថិតនៅក្នុងទង្វើគោរពសក្ការៈនោះតែម្តងទេ ?» អាមីរុល–មុមីនីន صلوات الله عليه والسلام មានវចនៈថា៖ «អល់ឡោះហ៍ عزّ وجلّ បានបញ្ជូនណាប៊ីមូហាំម៉ាដ់ صلى الله عليه وآله وسلم មក ព្រមទាំងព្រះសាស្តា عليهم السلام ឯទៀត ដើម្បីអធិប្បាយបំភ្លឺខ្លឹមសារពិតនិងការបកស្រាយនិងមូលហេតុដែលបាំងនៅពីក្រោយវ៉ាហ៊ី (គឺការបើកឲ្យដឹងព្រះបន្ទូលអល់ឡោះហ៍ عزّ وجلّ) ហើយដើម្បីអធិប្បាយបំភ្លឺរបៀបធ្វើសក្ការបូជាអល់ឡោះហ៍ عزّ وجلّ ។» បុរសនោះបានទូលថា៖ «សូមព្រះអង្គ صلوات الله عليه والسلام ប្រាប់ទូលបង្គំផង តើស៊ូឡាត់មានអត្ថន័យដូចម្តេចទៅ ?» អាមីរុល–មុមីនីន صلوات الله عليه والسلام បានមានតបថា៖ «ពេលលោកថា៖ "អល់ឡហ៊ូ អាក់បារ៍" នៅក្នុងតាក់បៀរ៍ទុល អ៊ិះហ៊្រ៉ម (គឺនៅពេលចាប់ផ្តើមស៊ូឡាត់) មានន័យថាអល់ឡោះហ៍ عزّ وجلّ មហាធំថ្កើងបំផុត លើសពីការយល់ដឹងរបស់យើង ។ តាក់បៀរ៍ទីពីរ (គឺអល់ឡហ៊ូ អាក់បារ៍ទីពីរ) យើងព្រមទទួលស្គាល់អធិកភាពរបស់អល់ឡោះហ៍ عزّ وجلّ អធិកភាពនោះមិនអាចអធិប្បាយបានដោយប្រើមធ្យោបាយណាមួយបានឡើយ ។ យើងសូត្រតាក់បៀរ៍ទីបី

ដើម្បីទទួលស្គាល់ថា មិនអាចគូសវាសអល់ឡោះហ្ទ៍ عز وجل បានដោយទ្រង់ទ្រាយ ឬអាចស្រង់យករូបភាពព្រះអង្គ عز وجل បានឡើយ ។ ក្នុងតាក់បៀរ៍ទីបួន យើងទទួលស្គាល់ថាអល់ឡោះហ្ទ៍ عز وجل មានតាំងពីមុនដើមដំបូងបង្អស់នៃសម័យម្ល៉េះ ព្រះអង្គ عز وجل មិនរងការខូចអន់ថយឬការពុករលួយ ទ្រុឌទ្រោមឡើយ ។ ក្នុងតាក់បៀរ៍ទីប្រាំ យើងទទួលស្គាល់ថាមិនអាចស្គាល់សារធាតុដើមរបស់អល់ឡោះហ្ទ៍ عز وجل បានឡើយ ព្រះអង្គ عز وجل ស្ថិតនៅគ្រប់ទីកន្លែងដោយមិនបាច់ស្ថិតនៅក្នុងអ្វីមួយឡើយ ឬដោយមិនបាច់ឲ្យអ្វីមួយស្ថិតនៅក្នុងព្រះអង្គ عز وجل ឡើយ ។ ក្នុងតាក់បៀរ៍ទីប្រាំមួយ យើងទទួលស្គាល់ថា ព្រះគុណសម្បត្តិទាំងឡាយរបស់អល់ឡោះហ្ទ៍ عز وجل មិនផ្លាស់ប្ដូរទៅតាមពេលវេលាទេ ។ ក្នុងតាក់បៀរ៍ទីប្រាំពីរ យើងទទួលស្គាល់ថា យើងមិនអាចស្គាល់អល់ឡោះហ្ទ៍ عز وجل បានឡើយ តាមរយៈវិញ្ញាណទាំងប្រាំ (គឺសោតវិញ្ញាណ (ការឮ), ឃានវិញ្ញាណ (ការដឹងក្លិន), ជីវ្ហាវិញ្ញាណ (ការដឹងរសជាតិ), កាយវិញ្ញាណ (ការដឹងដោយប៉ះពាល់), ចក្ខុវិញ្ញាណ (ការមើលឃើញ)) របស់យើង ។ ចូរលោកដកក ពេលលោកលំឱនកាយ (គឺរូកុអ៍) ចូរប្រគល់ក្បាលលោកឲ្យគេកាត់



ដើម្បីមូលហេតុអល់ឡោះហ្ទ៍ عز وجل ។ នៅពេលងើបក្បាលឡើងវិញហើយឈរត្រង់ខ្លួន យើងសូត្រថា៖ "សាមីអ៊ុលឡ៊ហ៊ូ លីម៉ាន់ ហាមីដ្ទាស់" (អល់ឡោះហ្ទ៍ عز وجل ឮបណ្ដាអ្នកស្ញើច សរសើរព្រះអង្គ عز وجل) ហើយចូរអរព្រះគុណអល់ឡោះហ្ទ៍ عز وجل ដែលធ្វើឲ្យយើងមានជីវិតចេញមកពីភាពគ្មានជីវិត ។ ពេលក្រាបប្រណិប័តន៍ដំបូង (គឺស៊ូជូដទីមួយ) យើងសូមថ្វាយការក្រាបប្រណិប័តន៍នេះចំពោះព្រះអង្គ عز وجل ទទួលស្គាល់ថាអល់ឡោះហ្ទ៍ عز وجل បានបង្កើតយើងមកអំពីធូលី ហើយចូរអរព្រះគុណព្រះអង្គ عز وجل [ពេលងើបក្បាលពីក្រាបប្រណិប័តន៍វិញ] ដែលព្រះអង្គ عز وجل បានយកយើងចេញពីដី ។ ពេលក្រាបប្រណិប័តន៍ទីពីរ យើងទទួលស្គាល់ថាយើងនឹងស្លាប់ហើយនឹងទៅជាធូលីមួយប៉ែក ពេលយើងងើបក្បាលឡើងវិញ យើងសូមទទួលស្គាល់ថាព្រះអង្គ عز وجل នឹងឲ្យយើងរស់ឡើងវិញ ។ ពេលលោកអង្គុយលើខាងឆ្វេង ខ្លួនដោយដាក់ជើងស្ដាំលើបាតជើងឆ្វេងជាសញ្ញាបញ្ជាក់ថាយើងនៅលើមាគ៌ាត្រង់ត្រូវ ហើយបានកម្ចាត់វិរុទ្ធភាព ។ នៅក្នុង "តាសាហ្ហ៊ុដ" លោកប្រកាសជាថ្មីនូវអ៊ីម៉ាន់លោក (គឺសច្ចាថាលោកនៅតែមានអ៊ីម៉ាន់ដដែល) ប្រតិបត្តិសាសនា